# សន្និសីទអន្តរជាតិស្តីពីអាជីវកម្មរ៉ែ
# “ឱកាសសម្រាប់កម្ពុជា”
## ភ្នំពេញ ថ្ងៃទី ២៦-២៧ ខែ ឧសភា ឆ្នាំ ២០១០

# របបសារពើពន្ធប្រៀបធៀប

បប់ ផាសុនស៏

ភ្នំពេញ

២៦-២៧ ឧសភា ឆ្នាំ ២០១០

# បញ្ហាជារួមនៃសារពើពន្ធ

- ការគ្រប់គ្រងក្តីរំពឹងអំពីផលប្រយោជន៍
- ការចូលរួមរបស់រដ្ឋាភិបាលនៅក្នុងវិស័យអាជីវកម្មរ៉ែ
- កត្តាលើកទឹកចិត្តផ្នែកសារពើពន្ធ
- ការអនុវត្តល្អៗពីអន្តរជាតិចំពោះការយកពន្ធនិងពន្ធសួយសារ

# ការគ្រប់គ្រងក្តីរំពឹងអំពីផលប្រយោជន៍

*លំហូរសាច់ប្រាក់-ជីវិតនៃគម្រោង*



# ការគ្រប់គ្រងក្តីរំពឹងអំពីផលប្រយោជន៍

- ប្រភពចំណូលចំបងសម្រាប់រដ្ឋាភិបាលៈ
  - ពន្ធសួយសារ
  - ពន្ធប្រាក់លើចំណេញ
- ចរន្តពន្ធសួយសារៈ ពេលចាប់ផ្តើមផលិត
- ចរន្តពន្ធប្រាក់ចំណេញៈ ក្រោយពេលចាប់ផ្តើមផលិត
- ដំណាក់កាលរុករកនិងអភិវឌ្ឍន៏គម្រោងៈ ចរន្តចំណូលរបស់រដ្ឋាភិបាលពុំមានច្រើនឡើយ

# ការចូលរួមរបស់រដ្ឋាភិបាលនៅក្នុងវិស័យអាជីវកម្មរ៉ែ

- តើ "អត្រាពន្ធពិត" ដែលអាចទទួលយកបានគឺជាអ្វី?
- តើរដ្ឋាភិបាលគប្បីដាក់ទុនវិនិយោគក្នុងវិស័យអាជីវកម្មរ៉ែដែរឬទេ?

# អត្រាពន្ធពិត

*ការបែងចែកចំណូលគម្រោងជាក់លាក់ក្នុងអំឡុងជីវិតនៃគម្រោង*

ពន្ធពិតអាចមានអត្រាខ្ពស់ជាង ៥០ ភាគរយ



# តើរដ្ឋាភិបាលគប្បីដាក់ទុនវិនិយោគ ក្នុងវិស័យអាជីវកម្មវ៉ែដែរឬទេ?

**ហេតុផលដែលគាំទ្រការដាក់ទុនរបស់រដ្ឋាភិបាលក្នុងអាជីវកម្មរ៉ែ:**

- ផ្តល់ឱកាសដល់ប្រជាពលរដ្ឋឱ្យបានទទួលផលដោយផ្ទាល់ពីសម្បត្តិដែលគម្រោងបានបង្កើត
- ផ្តល់មធ្យោបាយដែលរដ្ឋាភិបាលអាចចូលរួមក្នុងកម្រិតនៃការសម្រេចចិត្ត និងការព្រមព្រៀង នៅកម្រិតសាជីវកម្ម តាមរយៈក្រុមប្រឹក្សាភិបាល
- ផ្តល់មធ្យោបាយដែលរដ្ឋាភិបាលអាចទទួលព័ត៌មានអំពីគម្រោង ពុំនោះសោតពុំអាចទទួលបានដោយស្រួលនោះទេ

# តើរដ្ឋាភិបាលគប្បីដាក់ទុនវិនិយោគ ក្នុងវិស័យអាជីវកម្មរ៉ែដែរឬទេ?

## ហេតុផលដែលមិនគាំទ្រចំពោះការដាក់ទុនរបស់រដ្ឋាភិបាលក្នុងអាជីវកម្មរ៉ែ:

១. ខណៈដែលរដ្ឋាភិបាលមិនយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវ ចំណូលពីការវិនិយោគរបស់ក្រុមហ៊ុន រងផលប៉ះពាល់អវិជ្ជមាន

២. ខណៈដែលរដ្ឋាភិបាលយកចិត្តទុកដាក់បានត្រឹមត្រូវ តាមធម្មតា គេប្រើបានល្អប្រសើរនូវហិរញ្ញវត្ថុ ដែលជាធនធានកម្រ លើមុខងារដែលរដ្ឋាភិបាលតែងអនុវត្ត ដូចជា អប់រំ សុខាភិបាល ។ល។

៣. ការដាក់ទុនរបស់រដ្ឋាភិបាលក្នុងគម្រោងអាជីវកម្មរ៉ែគឺជាវិធីមួយដែលមានហានិភ័យខ្ពស់ ធៀបនឹងការយកពន្ធសួយសារ ឬពន្ធលើប្រាក់ចំណេញ

៤. បទពិសោធន៍បង្ហាញថា ខណៈដែលរដ្ឋាភិបាលសម្រេចចិត្តដកខ្លួនពីចំណាប់អារម្មណ៍ ការដកខ្លួនពីការវិនិយោគ អាចជាដំណើរការដែលមានលក្ខណៈស្មុគស្មាញ ត្រូវចំណាយពេលវេលា និងចំណាយច្រើន ។

# តើរដ្ឋាភិបាលគប្បីដាក់ទុនវិនិយោគ ក្នុងវិស័យអាជីវកម្មរ៉ែដែរឬទេ?

**អំណះអំណាងដែលជំទាស់ជាមួយ ការរួមហ៊ុនរបស់រដ្ឋាភិបាល (ត)៖**

៥. វិនិយោគិនមានទំនោរចង់វិនិយោគលើគម្រោងអាជីវកម្មរ៉ែ ដែលរដ្ឋាភិបាលពុំមែនជាសហ-វិនិយោគិន។ វិនិយោគិនយល់ថាការចូលរួមរបស់រដ្ឋាភិបាលធ្វើឱ្យយឺតយ៉ាវដល់ដំណើរការនៃការសម្រេចចិត្តនៅកម្រិតសហគ្រាស ហើយធ្វើឱ្យវិនិយោគិនដទៃបាត់បង់ការទាក់ទាញក្នុងការវិនិយោគលើគម្រោងនោះ។

៦. ការរួមទុនរបស់រដ្ឋាភិបាលអាចធ្វើឱ្យមានទំនាស់រវាងវិនិយោគិននិងរដ្ឋាភិបាល ដូចជាទំនាស់ស្ដីពីគោលនយោបាយទូទាត់ភាគលាភ

៧. រដ្ឋាភិបាលបានចូលរួមរួចហើយនៅក្នុងគម្រោងតាមរយៈការប្រមូលពន្ធលើប្រាក់ចំណេញ ពន្ធសួយសារ និងអាករដទៃទៀត

**ដោយសារមូលហេតុទាំងនេះ និន្នាការទូទៅគឺជៀសវាងពីការចូលរួមទុនពីរដ្ឋាភិបាល**

# កត្តាលើកទឹកចិត្តផ្នែកសារពើពន្ធ

- កត្តាលើកទឹកចិត្តដែលគេនិយមប្រើ៖
  - ការលើកលែងពន្ធ
  - ការកាត់បន្ថយអត្រាពន្ធ
- ការសិក្សានានាបង្ហាញថាកត្តាលើកទឹកចិត្តដែលគេនិយមប្រើទាំងនេះ នៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ
- និន្នាការកាលពីពេលថ្មីៗ៖
  - "កត្តាលើកទឹកចិត្ត" ផ្នែកសារពើពន្ធប្រសើរបំផុតគឺការកាត់បន្ថយចំណាយមូលធន

# បទពិសោធន៍ល្អប្រសើរអន្តរជាតិ

- ការប្រកួតប្រជែងដើម្បីទាក់ទាញការវិនិយោគមានភាពស្រួចស្រាល់
- របបសារពើពន្ធមានផលប៉ះពាល់ចំពោះការសម្រេចចិត្តអំពីការវិនិយោគ
- របបសារពើពន្ធត្រូវតែមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ
- អត្រាពន្ធនិងអត្រាពន្ធសួយសារ និងវិធាននានាគប្បីមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ

- ឧទាហរណ៍ អត្រាពន្ធលើកប្រាក់ចំណេញពី ២៥-៣៥ ភាគរយ

អត្រាពន្ធសួយសារពី ១-៣ ភាគរយនៃពន្ធសួយសារសរុប

ការអនុគ្រោះពន្ធដែលអនុញ្ញាតឱ្យរំលស់មូលធនក្នុងអត្រាខ្ពស់

ធ្វើឱ្យវិធាននានាមានលក្ខណៈសាមញ្ញ ងាយយល់ និងងាយគ្រប់គ្រង

# ពិភាក្សា